**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តស្ទឹងត្រែង**

សំណុំរឿងរដ្ឋប្បវេណីលេខ ៦៤
ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២០
សាលក្រមរដ្ឋប្បវេណីលេខ ៤៣ (ក)
ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២០

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តស្ទឹងត្រែង**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២០។

**ចៅក្រមជំនុំជម្រះ**

ឯកឧត្តមបណ្ឌិត [redacted] ចៅក្រម សាលាដំបូងខេត្តស្ទឹងត្រែង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តស្ទឹងត្រែង

ដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ភេទស្រី អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ មុខរបរ មេផ្ទះ ទីលំនៅបច្ចុប្បន្ន [redacted]។

មេធាវីតំណាងដោយអាណត្តិ លោក [redacted]។

ចុងចម្លើយឈ្មោះ [redacted] សុផល ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរ មន្ត្រីរាជការ ទីលំនៅបច្ចុប្បន្ន [redacted]។

មេធាវីតំណាងដោយអាណត្តិ គ្មាន។

**ខ្លឹមសារនៃសាលក្រមដែលដើមចោទសុំឱ្យតុលាការសម្រេចៈ**

១-លែងលះដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ពីចុងចម្លើយឈ្មោះ [redacted] សុផល។

២-ឱ្យដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ជាអ្នកមានអំណាចមេបាលើកូនស្រីឈ្មោះ [redacted] ផល្លីយ៉ា អាយុជាង ២ខែ

៣-ឱ្យដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ជាអ្នកមានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិរួម ដីលំនៅឋាន ចំនួន ១ (មួយ) ឡូតិ៍ ទទឹងប្រវែង ៥ម៉ែត្រ និងបណ្តោយប្រវែង ១៨ម៉ែត្រ ស្ថិត នៅភូមិថ្មលាត សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង និង

៤-ឱ្យដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ជាអ្នកទទួលសងបំណុលរួមនៅជំពាក់ ធនាគារ ហិត្ថា ចំនួន ៣ ៦៤៤,១២ (បីពាន់ប្រាំមួយរយសែសិបបួនក្បៀសដប់ពីរ) ដុល្លារអាមេរិក។

៥-បែងចែកទ្រព្យសម្បត្តិរួម រថយន្ត ម៉ាក Prius ផលិតឆ្នាំ២០០៥ ពណ៌ស ពាក់ស្លាក លេខ សៀមរាប 2C-9771 ជាពីរចំណែកស្មើៗគ្នា។

៦-ឱ្យចុងចម្លើយឈ្មោះ [redacted] សុផល ជាអ្នកមានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិរួម ម៉ូតូម៉ាក HONDA ZOMMER X ផលិតឆ្នាំ២០២០ ពណ៌ស មិនចាំស្លាកលេខ និង

៧-ឱ្យចុងចម្លើយឈ្មោះ [redacted] សុផល ជាអ្នកមានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិរួម ដីលំនៅឋាន ចំនួន ១ (មួយ) ឡូតិ៍ ទទឹងប្រវែង ៥ម៉ែត្រ និងបណ្តោយប្រវែង ១៨ម៉ែត្រ ស្ថិតនៅភូមិថ្មលាត សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

## អង្គហេតុ និងចំណុចវិវាទ

នៅក្នុងពាក្យបណ្តឹងចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី បានឱ្យដឹងថា កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩ ដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី និងចុងចម្លើយឈ្មោះ [redacted] សុផល បានរៀបអាពាហ៍ពិពាហ៍ នៅភូមិកណ្តាល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។ ក្នុងពេលរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ មានកូនស្រីម្នាក់ឈ្មោះ [redacted] ផល្លីយ៉ា អាយុជាង ២ខែ មានទ្រព្យសម្បត្តិរួមៈ

១-ដីលំនៅឋានចំនួន ២ (ពីរ) ឡូតិ៍ ក្នុងមួយៗឡូតិ៍ ទទឹងប្រវែង ៥ម៉ែត្រ និងបណ្តោយប្រវែង ១៨ម៉ែត្រ ស្ថិតនៅភូមិថ្មលាត សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង

២-រថយន្តម៉ាក Prius ផលិតឆ្នាំ២០០៥ ពណ៌ស ពាក់ស្លាកលេខ សៀមរាប 2C-9771 និង

៣-ម៉ូតូម៉ាក HONDA ZOMMER X ផលិតឆ្នាំ២០២០ ពណ៌ស ស្លាកលេខ ស្ទឹងត្រែង 1C-9769 និងមានបំណុលរួមនៅជំពាក់ ធនាគារ ហត្ថា ចំនួន ៣ ៦៤៤,១២ (បីពាន់ប្រាំមួយរយសែសិបបួនក្បៀសដប់ពីរ) ដុល្លារអាមេរិក។ ក្នុងឆ្នាំ២០២០ ដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី និងចុងចម្លើយឈ្មោះ [redacted] សុផល បានរស់នៅមិនចុះសម្រុងនឹងគ្នាដែលជាហេតុធ្វើឱ្យដើមចោទឈ្មោះ ស៊ូ សុវណ្ណម៉ាលី អស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នាជាប្តីប្រពន្ធបន្តទៅទៀត ទើបនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២០ ដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី បានមកដាក់ពាក្យបណ្តឹងនៅសាលាដំបូងខេត្តស្ទឹងត្រែង សុំឱ្យតុលាការចេញសាលក្រមសម្រេចៈ

ក-លែងលះដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ពីចុងចម្លើយឈ្មោះ [redacted] សុផល។

ខ-ឱ្យដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ជាអ្នកមានអំណាចមេបាលើកូនស្រីឈ្មោះ [redacted] ផល្លីយ៉ា អាយុជាង ២ខែ

គ-ឱ្យដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ជាអ្នកមានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិរួម ដីលំនៅឋាន ចំនួន ១ (មួយ) ឡូតិ៍ ទទឹងប្រវែង ៥ម៉ែត្រ និងបណ្តោយប្រវែង ១៨ម៉ែត្រ ស្ថិត នៅភូមិថ្មលាត សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង និង

ឃ-ឱ្យដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ជាអ្នកទទួលសងបំណុលរួមនៅជំពាក់ ធនាគារ ហត្ថា ចំនួន ៣ ៦៤៤,១២ (បីពាន់ប្រាំមួយរយសែសិបបួនក្បៀសដប់ពីរ) ដុល្លារអាមេរិក។

ង-បែងចែកទ្រព្យសម្បត្តិរួម រថយន្ត ម៉ាក Prius ផលិតឆ្នាំ២០០៥ ពណ៌ស ពាក់ស្លាកលេខ សៀមរាប 2C-9771 ជាពីរចំណែកស្មើៗគ្នា។

ច-ឱ្យចុងចម្លើយឈ្មោះ [redacted] សុផល ជាអ្នកមានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិរួម ម៉ូតូម៉ាក HONDA ZOMMER X ផលិតឆ្នាំ២០២០ ពណ៌ស មិនចាំស្លាកលេខ និង



Scanned with CamScanner

ឆ-ឱ្យចុងចម្លើយឈ្មោះ [redacted] សុផល ជាអ្នកមានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិរួម ដីលំនៅឋាន ចំនួន ១ (មួយ) ឡូតិ៍ ទទឹងប្រវែង ៥ម៉ែត្រ និងបណ្តោយប្រវែង ១៨ម៉ែត្រ ស្ថិតនៅភូមិថ្មលាត សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

**សេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទ**

លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី បានធ្វើសេចក្តីថ្លែងការណ៍ថា: កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩ កូនក្តីរបស់ខ្ញុំបាទឈ្មោះ [redacted] សុវណ្ណម៉ាលី និងចុងចម្លើយឈ្មោះ [redacted] សុផល បានរៀបអាពាហ៍ពិពាហ៍ នៅភូមិកណ្តាល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។ នៅពេលរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ មានកូនស្រីឈ្មោះ [redacted] ផល្លីយ៉ា អាយុ ៣ខែ មានទ្រព្យសម្បត្តិរួម៖

១-ដីលំនៅឋានចំនួន ២ (ពីរ) ឡូតិ៍ ក្នុងមួយៗឡូតិ៍ ទទឹងប្រវែង ៥ម៉ែត្រ និងបណ្តោយប្រវែង ១៨ម៉ែត្រ ស្ថិតនៅភូមិថ្មលាត សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង

២-រថយន្ត ម៉ាក Prius ផលិតឆ្នាំ២០០៥ ពណ៌ស ពាក់ស្លាកលេខ សៀមរាប 2C-9771 និង

៣-ម៉ូតូម៉ាក HONDA ZOMMER X ផលិតឆ្នាំ២០២០ ពណ៌ស ពាក់ស្លាកលេខ ស្ទឹងត្រែង 1C-9769 និងមានបំណុលរួម នៅជំពាក់ធនាគារ ហត្ថា សរុបចំនួន ៣ ៦៤៤,១២ (បីពាន់ប្រាំមួយរយសែសិបបួនក្បៀសដប់ពីរ) ដុល្លារអាមេរិក។ នៅក្នុងឆ្នាំ២០២០ កូនក្តីរបស់ខ្ញុំបាទឈ្មោះ [redacted] សុវណ្ណម៉ាលី និងចុងចម្លើយឈ្មោះ [redacted] សុផល បានរស់នៅមិនចុះសម្រុងនឹងគ្នា ដែលជាហេតុធ្វើឱ្យកូនក្តីរបស់ខ្ញុំបាទឈ្មោះ [redacted] សុវណ្ណម៉ាលី អស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នាជាប្តីប្រពន្ធតទៅទៀត ទើបនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២០ កូនក្តីរបស់ខ្ញុំបាទឈ្មោះ [redacted] សុវណ្ណម៉ាលី បានមកដាក់ពាក្យបណ្តឹង នៅសាលាដំបូងខេត្តស្ទឹងត្រែង សុំតុលាការចេញសាលក្រមសម្រេច៖

ក-លែងលះដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ពីចុងចម្លើយឈ្មោះ [redacted] សុផល។

ខ-ឱ្យដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ជាអ្នកមានអំណាចមេបាលើកូនស្រីឈ្មោះ [redacted] ផល្លីយ៉ា អាយុជាង ២ខែ

គ-ឱ្យដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ជាអ្នកមានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិរួម ដីលំនៅឋាន ចំនួន ១ (មួយ) ឡូតិ៍ ទទឹងប្រវែង ៥ម៉ែត្រ និងបណ្តោយប្រវែង ១៨ម៉ែត្រ ស្ថិត នៅភូមិថ្មលាត សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង និង

ឃ-ឱ្យដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ជាអ្នកទទួលសងបំណុលរួមនៅជំពាក់ ធនាគារហត្ថា ចំនួន ៣ ៦៤៤,១២ (បីពាន់ប្រាំមួយរយសែសិបបួនក្បៀសដប់ពីរ) ដុល្លារអាមេរិក។

ង-បែងចែកទ្រព្យសម្បត្តិរួម រថយន្ត ម៉ាក Prius ផលិតឆ្នាំ២០០៥ ពណ៌ស ពាក់ស្លាកលេខ សៀមរាប 2C-9771 ជាពីរចំណែកស្មើៗគ្នា។

ច-ឱ្យចុងចម្លើយឈ្មោះ [redacted] សុផល ជាអ្នកមានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិរួម ម៉ូតូម៉ាក HONDA ZOMMER X ផលិតឆ្នាំ២០២០ ពណ៌ស មិនចាំស្លាកលេខ និង



Scanned with CamScanner

ឆ-ឱ្យចុងចម្លើយឈ្មោះ [redacted] សុផល ជាអ្នកមានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិរួមដីលំនៅឋាន ចំនួន ១ (មួយ) ឡូតិ៍ ទទឹងប្រវែង ៥ម៉ែត្រ និងបណ្តោយប្រវែង ១៨ម៉ែត្រ ស្ថិតនៅភូមិថ្មលាត សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។ ប៉ុន្តែនៅពេលនេះ កូនក្តីរបស់ខ្ញុំបាទឈ្មោះ [redacted] សុវណ្ណម៉ាលី សុំឱ្យតុលាការចេញសាលក្រម សម្រេចប្រគល់ទ្រព្យសម្បត្តិរួម រថយន្តម៉ាក Prius ផលិតឆ្នាំ២០០៥ ពណ៌ស ពាក់ស្លាកលេខ សៀមរាប 2C-9771 ឱ្យទៅចុងចម្លើយឈ្មោះ [redacted] សុផល ជាអ្នកមានសិទ្ធិចាត់ចែង ហើយសុំឱ្យតុលាការចេញសាលក្រមសម្រេចឱ្យកូនក្តីរបស់ខ្ញុំបាទឈ្មោះ [redacted] សុវណ្ណម៉ាលី ជាអ្នកមានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិរួម ដីលំនៅឋានទាំង ២ (ពីរ) ឡូតិ៍។

**សេចក្តីថ្លែងការណ៍តបរបស់ចុងចម្លើយ**

ចុងចម្លើយឈ្មោះ [redacted] សុផល ធ្វើសេចក្តីថ្លែងការណ៍តបថា ខ្ញុំបាទយល់ព្រមតាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ទាំងអស់ ពុំមានជំទាស់ត្រង់ចំណុចណាមួយឡើយ។

## សំអាងហេតុ

១-កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩ ដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី និងចុងចម្លើយឈ្មោះ [redacted] សុផល បានរៀបអាពាហ៍ពិពាហ៍ នៅភូមិកណ្តាល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។ ក្នុងពេលរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ ដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី និងចុងចម្លើយឈ្មោះ [redacted] សុផល មានកូនស្រីឈ្មោះ [redacted] ផល្លីយ៉ា កើតថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ មានទ្រព្យសម្បត្តិរួម ដីលំនៅឋានចំនួន ២ (ពីរ) ឡូតិ៍ ក្នុងមួយៗឡូតិ៍ ទទឹងប្រវែង ៥ម៉ែត្រ និងបណ្តោយប្រវែង ១៨ម៉ែត្រ ស្ថិតនៅភូមិថ្មលាត សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង រថយន្តម៉ាក Prius ផលិតឆ្នាំ២០០៥ ពណ៌ស ពាក់ស្លាកលេខ សៀមរាប 2C-9771 និងម៉ូតូម៉ាក HONDA ZOMMER X ផលិតឆ្នាំ២០២០ ពណ៌ស ពាក់ស្លាកលេខ ស្ទឹងត្រែង 1C-9769 និងមានបំណុលរួមនៅជំពាក់ធនាគារ ហត្ថា សរុបចំនួន ៣ ៦៤៤,១២ (បីពាន់ប្រាំមួយរយសែសិបបួនក្បៀសដប់ពីរ) ដុល្លារអាមេរិក ប្រាកដមែន។

២-នៅក្នុងឆ្នាំ២០២០ ដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី និងចុងចម្លើយឈ្មោះ [redacted] សុផល បានរស់នៅមិនចុះសម្រុងនឹងគ្នា ហើយនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២០ ដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី បានមកដាក់ពាក្យបណ្តឹងនៅសាលាដំបូងខេត្តស្ទឹងត្រែង សុំឱ្យតុលាការចេញសាលក្រមសម្រេចៈ

ក-លែងលះដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ពីចុងចម្លើយឈ្មោះ [redacted] សុផល។

ខ-ឱ្យដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ជាអ្នកមានអំណាចមេបាលើកូនស្រីឈ្មោះ [redacted] ផល្លីយ៉ា អាយុជាង ២ខែ

គ-ឱ្យដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ជាអ្នកមានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិរួម ដីលំនៅឋានចំនួន ១ (មួយ) ឡូតិ៍ ទទឹងប្រវែង ៥ម៉ែត្រ និងបណ្តោយប្រវែង ១៨ម៉ែត្រ ស្ថិត នៅភូមិថ្មលាត សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង និង

ឃ-ឱ្យដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ជាអ្នកទទួលសងបំណុលរួមនៅជំពាក់ ធនាគារហត្ថា ចំនួន ៣ ៦៤៤,១២ (បីពាន់ប្រាំមួយរយសែសិបបួនក្បៀសដប់ពីរ) ដុល្លារអាមេរិក។

ង-បែងចែកទ្រព្យសម្បត្តិរួម រថយន្ត ម៉ាក Prius ផលិតឆ្នាំ២០០៥ ពណ៌ស ពាក់ស្លាកលេខ សៀមរាប 2C-9771 ជាពីរចំណែកស្មើៗគ្នា។



Scanned with CamScanner

ច-ឱ្យចុងចម្លើយឈ្មោះ [redacted] សុផល ជាអ្នកមានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិរួម ម៉ូតូម៉ាក HONDA ZOMMER X ផលិតឆ្នាំ២០២០ ពណ៌ស មិនចាំស្លាកលេខ និង

ឆ-ឱ្យចុងចម្លើយឈ្មោះ [redacted] សុផល ជាអ្នកមានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិរួមដីលំនៅឋានចំនួន ១ (មួយ) ឡូតិ៍ ទទឹងប្រវែង ៥ម៉ែត្រ និងបណ្តោយប្រវែង ១៨ម៉ែត្រ ស្ថិតនៅភូមិថ្មលាត សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ប្រាកដមែន។

៣-នៅពេលទាញហេតុផលដោយផ្ទាល់មាត់ មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី បានធ្វើសេចក្តីថ្លែងការណ៍ សុំតុលាការចេញសាលក្រមសម្រេច ប្រគល់ទ្រព្យសម្បត្តិរួម រថយន្ត ម៉ាក Prius ផលិតឆ្នាំ២០០៥ ពណ៌ស ពាក់ស្លាកលេខ សៀមរាប 2C-9771 ឱ្យចុងចម្លើយឈ្មោះ [redacted] សុផល ជាអ្នកមានសិទ្ធិចាត់ចែង និងសុំឱ្យតុលាការចេញសាលក្រមសម្រេចឱ្យកូនក្តីរបស់គាត់ឈ្មោះ [redacted] សុវណ្ណ ជាអ្នកមានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិរួម ដីលំនៅឋាន ចំនួន ២ (ពីរ) ឡូតិ៍ ហើយចុងចម្លើយឈ្មោះ [redacted] សុផល ក៏បានយល់ព្រមតាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ដែរ។ ដូចនេះតុលាការគប្បីលើកយកមកពិចារណា។

## សេចក្តីសម្រេចបញ្ចប់

១-ទទួលស្គាល់ពាក្យបណ្តឹងចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ធ្វើឡើងត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-លែងលះដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ពីចុងចម្លើយឈ្មោះ [redacted] សុផល។ ប៉ុន្តែដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ប្រសិនបើអំឡុងពេល ១២០ (មួយរយម្ភៃ) ថ្ងៃ ពុំទាន់កន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុន ត្រូវបានរំលាយ។

៣-ឱ្យដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ជាអ្នកមានអំណាចមេបាលើកូនស្រីឈ្មោះ [redacted] ផល្លីយ៉ា កើតនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ។ ប៉ុន្តែចុងចម្លើយឈ្មោះ [redacted] សុផល មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។

៤-ឱ្យដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ជាអ្នកមានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិរួម ដីលំនៅឋានចំនួន ២ (ពីរ) ឡូតិ៍ ក្នុងមួយៗឡូតិ៍ ទទឹងប្រវែង ៥ម៉ែត្រ និងបណ្តោយប្រវែង ១៨ម៉ែត្រ ស្ថិតនៅភូមិថ្មលាត សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង

៥-ឱ្យដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី ជាអ្នកទទួលសងបំណុលនៅធំពាក់ ធនាគា ហ៊ិត្ថា ចំនួន ៣ ៦៤៤,១២ (បីពាន់ប្រាំមួយរយសែសិបបួនក្បៀសដប់ពីរ) ដុល្លារអាមេរិក។

៦-ឱ្យចុងចម្លើយឈ្មោះ [redacted] សុផល ជាអ្នកមានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិរួម៖

ក-រថយន្ត ម៉ាក Prius ផលិតឆ្នាំ២០០៥ ពណ៌ស ពាក់ស្លាកលេខ សៀមរាប 2C-9771 និង

ខ-ម៉ូតូម៉ាក HONDA ZOMMER X ផលិតឆ្នាំ២០២០ ពណ៌ស ពាក់ស្លាកលេខ ស្ទឹងត្រែង 1C-9769 ។

៧-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅចំពោះមុខមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] សុវណ្ណម៉ាលី និងចុងចម្លើយឈ្មោះ [redacted] សុផល។ បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់។



Scanned with CamScanner

ថ្ងៃពុធ ២រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅស្ទឹងត្រែង, ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២០

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃពុធ ២រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅស្ទឹងត្រែង, ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

**បណ្ឌិត** [redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ស្ទឹងត្រែង, ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]